សុខភាព និងជីវិត
កាន់តែប្រសើរ

# AIA សម្រាប់សុខភាព

## ដំណោះស្រាយសុខភាពពេញមួយជីវិត ដំបូងគេនៅកម្ពុជា

ថ្មី!



សុខភាពរបស់អ្នកគឺជាទ្រព្យសម្បត្តិដ៏មានតម្លៃបំផុត! ហេតុដូចនេះ អ្នកគួរតែទទួលបានការការពារដ៏ល្អបំផុត នៅពេលដែលអ្នកគិតគូរពីសុខភាពរបស់អ្នក។ការរៀបចំគម្រោងហិរញ្ញវត្ថុសម្រាប់សុខភាពដ៏ត្រឹមត្រូវពិតជាមានសារៈសំខាន់ ហើយអាចផ្តល់នូវការការពារសុខភាពដល់អ្នកតាមតម្រូវការយ៉ាងពេញលេញ។ អ្នកអាចធានាបានលើការចំណាយព្យាបាលជំងឺពីហោប៉ៅផ្ទាល់ខ្លួនក្នុងចំនួនតិចបំផុត ជាជំនួយយ៉ាងសំខាន់ផ្នែកហិរញ្ញវត្ថុភ្លាមៗដ៏មានតម្លៃដែលអាចជួយសម្រាលបន្ទុកលើចំណាយព្យាបាលជំងឺឱ្យបានទាន់ពេលវេលា តាំងពីការធ្វើរោគវិនិច្ឆ័យ រហូតដល់ ការព្យាបាលជាសះស្បើយឡើងវិញ។

# ហេតុអ្វី AIA សម្រាប់សុខភាព សំខាន់និងជាជម្រើសដ៏សក្តិសមបំផុតសម្រាប់អ្នក?

AIA សម្រាប់សុខភាព ជាដំណោះស្រាយសុខភាពពេញមួយជីវិតដំបូងគេនៅកម្ពុជា ដែលផ្តល់រង្វាន់លើកទឹកចិត្តសម្រាប់ការរស់នៅប្រកបដោយសុខភាពល្អ។

### ដំបូងគេបង្អស់នៅលើទីផ្សារកម្ពុជា

**គម្រោងធានារ៉ាប់រងសុខភាពពេញមួយជីវិត**

ធានាបន្តផ្តល់សុពលភាព ដែលមានតម្លៃសមរម្យត្រឹមតែ 2,000រៀល* តែប៉ុណ្ណោះក្នុងមួយថ្ងៃ

### ដំបូងគេបង្អស់នៅលើទីផ្សារកម្ពុជា

**ការលើកទឹកចិត្តសម្រាប់ការមិនទាមទារសំណង**

សម្រាប់ការរស់នៅប្រកបដោយសុខភាពល្អ សម្រាប់ប្រើប្រាស់លើការពិនិត្យសុខភាព ការចាក់ថ្នាំបង្ការជំងឺផ្សេងៗ ការថែទាំសុខភាពមាត់ធ្មេញជាដើម

### បណ្តាញមន្ទីរពេទ្យដែលប្រកបដោយគុណភាពនៅក្នុង និងក្រៅប្រទេស

- បណ្តាញមន្ទីរពេទ្យប្រកបដោយគុណភាពទាំងក្នុង និងក្រៅប្រទេស ជាមួយនឹងបទពិសោធន៍ទូទាត់ថ្លៃចំណាយដោយមិនប្រើប្រាស់សាច់ប្រាក់
- ការពិគ្រោះយោបល់ផ្នែកវេជ្ជសាស្ត្រផ្ទាល់ខ្លួន និងការណែនាំអំពីមតិទីពីរពីអ្នកជំនាញនៅក្រៅប្រទេស**

**បុព្វលាភសម្រាប់មនុស្សប្រុស អាយុ 30 ឆ្នាំ គម្រោង 50K*
***សេវាកម្មនេះមិនរាប់បញ្ចូលថ្លៃធ្វើដំណើរ និងថ្លៃព្យាបាលទេ*

# តារាងអត្ថប្រយោជន៍សម្រាប់គម្រោងដំណោះស្រាយសុខភាព

| គម្រោងធានារ៉ាប់រង | គម្រោង 50K | គម្រោង 150K | គម្រោង 500K | គម្រោង 1M | គម្រោង 1.5M |
|---|---|---|---|---|---|
| អាយុដែលត្រូវបានទទួលយកការធានារ៉ាប់រង | 30 ថ្ងៃ ដល់ 69 ឆ្នាំ (អាយុផុតកំណត់: 100 ឆ្នាំ) | | | | |
| រយៈពេលនៃបណ្ណសន្យារ៉ាប់រង | ពេញមួយជីវិត | | | | |
| ទីតាំងភូមិសាស្ត្រនៃការធានា | ប្រទេសកម្ពុជា ថៃ វៀតណាម និង ម៉ាឡេស៊ី | ទូទាំងអាស៊ាន | ទូទាំងទ្វីបអាស៊ី | ទូទាំងតំបន់អាស៊ីប៉ាស៊ីហ្វិក | ទូទាំងពិភពលោក មិនរាប់បញ្ចូលសហរដ្ឋអាមេរិក |
| កម្រិតអតិបរមាប្រចាំឆ្នាំ | US$50,000 | US$150,000 | US$500,000 | US$1,000,000 | US$1,500,000 |
| កម្រិតអតិបរមាក្នុងមួយជីវិត | US$100,000 | US$300,000 | US$1,000,000 | US$2,000,000 | US$3,000,000 |
| កម្រិតមិនធ្វើសំណង (សម្រាប់ 1 ឆ្នាំ) | US$5,000/US$10,000/US$20,000 | | | | |
| | ផលិតផលធានារ៉ាប់រងមូលដ្ឋាន | | | | |
| **មរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍** | US$5,000 | US$15,000 | US$50,000 | US$100,000 | US$150,000 |
| | ផលិតផលធានារ៉ាប់រងបន្ថែមផ្នែកវិជ្ជាសាស្ត្រ | | | | |
| **(A) អត្ថប្រយោជន៍លើការសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ និងការវះកាត់** | | | | | |
| (i) អត្ថប្រយោជន៍លើតម្លៃសេវាបន្ទប់ និងគ្រែប្រចាំថ្ងៃ (រួមបញ្ចូលថ្លៃអាហារឱសថតាមវេជ្ជបញ្ជាថ្លៃវេជ្ជបណ្ឌិតព្យាបាល និងវេជ្ជបណ្ឌិតជំនាញឯកទេស ថ្លៃសេវាកម្មធ្វើរោគវិនិច្ឆ័យនិងការពិនិត្យតាមដានស្ថានភាពជំងឺនិងថ្លៃចំណាយផ្នែកវេជ្ជសាស្ត្រផ្សេងៗដែលពាក់ព័ន្ធនឹងការសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ) - រហូតដល់ 100 ថ្ងៃក្នុងមួយឆ្នាំនៃបណ្ណសន្យារ៉ាប់រងសម្រាប់សេវាបន្ទប់និងគ្រែ និងការព្យាបាលក្នុងផ្នែកសង្គ្រោះបន្ទាន់។ | រហូតដល់ US$50/ថ្ងៃ | រហូតដល់ US$100/ថ្ងៃ | រហូតដល់ US$200/ថ្ងៃ | រហូតដល់ US$300/ថ្ងៃ | រហូតដល់ US$400/ថ្ងៃ |
| (ii) អត្ថប្រយោជន៍លើការព្យាបាលក្នុងផ្នែកសង្គ្រោះបន្ទាន់ប្រចាំថ្ងៃ (រួមបញ្ចូលថ្លៃអាហារ ឱសថតាមវេជ្ជបញ្ជា ថ្លៃវេជ្ជបណ្ឌិតព្យាបាល និងវេជ្ជបណ្ឌិតជំនាញឯកទេស ថ្លៃសេវាកម្មធ្វើរោគវិនិច្ឆ័យ និងការពិនិត្យតាមដានស្ថានភាពជំងឺ និងថ្លៃចំណាយផ្នែកវេជ្ជសាស្ត្រ ផ្សេងៗដែលពាក់ព័ន្ធនឹងការសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ) - រហូតដល់ 100 ថ្ងៃក្នុងមួយឆ្នាំនៃបណ្ណសន្យារ៉ាប់រងសម្រាប់សេវាបន្ទប់និងគ្រែនិងការព្យាបាលក្នុងផ្នែកសង្គ្រោះបន្ទាន់។ | | | | | |
| (iii) អត្ថប្រយោជន៍លើការវះកាត់<br>(រួមបញ្ចូលថ្លៃបន្ទប់វះកាត់ និងថ្លៃវេជ្ជបណ្ឌិតចាក់ថ្នាំសណ្តំ ដែលចាំបាច់តាមការកំណត់របស់វេជ្ជបណ្ឌិតជំនាញឯកទេស ឬវេជ្ជបណ្ឌិតជំងឺទូទៅ ឬអ្នកជំនាញ)<br>• នីតិវិធីការវះកាត់<br>• ការវះកាត់ដាក់សម្ភារៈវេជ្ជសាស្ត្រដែលទទួលបានការអនុម័ត<br>• ការវះកាត់ដោយប្រើប្រាស់បច្ចេកទេសនៃ Stereotactic Radiosurgery | បង់ជូនពេញថ្លៃ | បង់ជូនពេញថ្លៃ | បង់ជូនពេញថ្លៃ | បង់ជូនពេញថ្លៃ | បង់ជូនពេញថ្លៃ |
| (iv) អត្ថប្រយោជន៍លើការផ្លាស់ប្តូរសរីរាង្គសំខាន់ៗ ឬការផ្លាស់ប្តូរខួរឆ្អឹង | | | | | |
| (v) អត្ថប្រយោជន៍លើគ្រែបន្ថែមសម្រាប់អាណាព្យាបាល ឬអ្នកកំដរ | | | | | |
| (vi) អត្ថប្រយោជន៍លើការថែទាំរបស់គិលានុបដ្ឋាកតាមផ្ទះ | មិនធានា | មិនធានា | រហូតដល់ US$1,000/ឆ្នាំ | រហូតដល់ US$1,500/ឆ្នាំ | រហូតដល់ US$2,000/ឆ្នាំ |

| | | | | | |
|---|---|---|---|---|---|
| (vii) អត្ថប្រយោជន៍លើការថែទាំជំងឺផ្លូវចិត្តសម្រាប់អ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ | មិនធានា | មិនធានា | បង់ជូនពេញថ្លៃ រហូតដល់កម្រិតអតិបរមាប្រចាំឆ្នាំ (រហូតដល់ 30 ថ្ងៃ) | | |
| (viii) អត្ថប្រយោជន៍លើការថែទាំអ្នកជំងឺដំណាក់ចុងក្រោយសម្រាប់អ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ | | | មិនធានា | មិនធានា | រហូតដល់ US$20,000 /មួយជីវិត |
| **(B) អត្ថប្រយោជន៍លើការព្យាបាលជំងឺដែលមិនចាំបាច់សម្រាកក្នុងមន្ទីរពេទ្យ (កម្រិតអតិបរមាប្រចាំឆ្នាំសម្រាប់ការព្យាបាលជំងឺដែលមិនចាំបាច់សម្រាកក្នុងមន្ទីរពេទ្យ)** | រហូតដល់ **US$7,500** | រហូតដល់ **US$22,500** | រហូតដល់ **US$75,000** | រហូតដល់ **US$150,000** | រហូតដល់ **US$225,000** |
| (i) អត្ថប្រយោជន៍លើការព្យាបាលជំងឺមុនចូលសម្រាកក្នុងមន្ទីរពេទ្យ (ក្នុងកំឡុងពេល 90 ថ្ងៃ មុនចូលសម្រាកក្នុងមន្ទីរពេទ្យ រួមបញ្ចូលថ្លៃប្រឹក្សាយោបល់ជាមួយអ្នកជំនាញ ការធ្វើរោគវិនិច្ឆ័យដោយប្រើប្រាស់កាំរស្មីអ៊ិច ឬការធ្វើតេស្តពិសោធន៍) | បង់ជូនពេញថ្លៃ រហូតដល់ កម្រិតអតិបរមាប្រចាំឆ្នាំ សម្រាប់ការព្យាបាលជំងឺដែលមិនចាំបាច់សម្រាកក្នុងមន្ទីរពេទ្យ | បង់ជូនពេញថ្លៃ រហូតដល់ កម្រិតអតិបរមាប្រចាំឆ្នាំ សម្រាប់ការព្យាបាលជំងឺដែលមិនចាំបាច់សម្រាកក្នុងមន្ទីរពេទ្យ | បង់ជូនពេញថ្លៃ រហូតដល់ កម្រិតអតិបរមាប្រចាំឆ្នាំ សម្រាប់ការព្យាបាលជំងឺដែលមិនចាំបាច់សម្រាកក្នុងមន្ទីរពេទ្យ | បង់ជូនពេញថ្លៃ រហូតដល់ កម្រិតអតិបរមាប្រចាំឆ្នាំ សម្រាប់ការព្យាបាលជំងឺដែលមិនចាំបាច់សម្រាកក្នុងមន្ទីរពេទ្យ | បង់ជូនពេញថ្លៃ រហូតដល់ កម្រិតអតិបរមាប្រចាំឆ្នាំ សម្រាប់ការព្យាបាលជំងឺដែលមិនចាំបាច់សម្រាកក្នុងមន្ទីរពេទ្យ |
| (ii) អត្ថប្រយោជន៍លើការព្យាបាលជំងឺក្រោយចូលសម្រាកក្នុងមន្ទីរពេទ្យ (ដែលកើតឡើងក្នុងកំឡុងពេល 90 ថ្ងៃ ក្រោយចូលសម្រាកក្នុងមន្ទីរពេទ្យ រួមបញ្ចូល ថ្លៃប្រឹក្សាយោបល់ជាមួយអ្នកជំនាញ ការព្យាបាលជំងឺដោយចលនាតាមវេជ្ជបញ្ជា ឬការធ្វើតេស្តពិសោធន៍) | | | | | |
| (iii) ការវះកាត់ដែលមិនសម្រាកក្នុងមន្ទីរពេទ្យ | | | | | |
| (iv) អត្ថប្រយោជន៍លើការព្យាបាលជំងឺមហារីក<br>• ការព្យាបាលជំងឺមហារីកដោយប្រើវិទ្យុសកម្ម (Radiotherapy)<br>• ការព្យាបាលជំងឺមហារីកដោយការចាក់គីមី (Chemotherapy) | | | | | |
| (v) អត្ថប្រយោជន៍លើការព្យាបាលជំងឺដោយការលាងឈាម | | | | | |
| **(C) អត្ថប្រយោជន៍លើការព្យាបាលជំងឺសង្គ្រោះបន្ទាន់** | | | | | |
| (i) អត្ថប្រយោជន៍លើការសង្គ្រោះបន្ទាន់ដែលបង្កឡើងពីគ្រោះថ្នាក់ចៃដន្យ | បង់ជូនពេញថ្លៃ | បង់ជូនពេញថ្លៃ | បង់ជូនពេញថ្លៃ | បង់ជូនពេញថ្លៃ | បង់ជូនពេញថ្លៃ |
| (ii) អត្ថប្រយោជន៍លើការព្យាបាលធ្មេញដែលបង្កឡើងពីគ្រោះថ្នាក់ចៃដន្យ | | | | | |
| (iii) អត្ថប្រយោជន៍លើរថយន្តគិលានសង្គ្រោះបន្ទាន់ | | | | | |
| (iv) អត្ថប្រយោជន៍លើការជម្លៀសទៅមន្ទីរពេទ្យសង្គ្រោះបន្ទាន់ និងសេវាដឹកត្រលប់មកវិញ | មិនធានា | មិនធានា | មិនធានា | មិនធានា | |
| **(D) សេវាគ្រប់គ្រង និងប្រឹក្សាការព្យាបាលផ្ទាល់ខ្លួន (PMCM)** | **ធានា** | **ធានា** | **ធានា** | **ធានា** | **ធានា** |
| **(E) អត្ថប្រយោជន៍លើថ្លៃព្យាបាលពេលសម្រាលកូន** | | | | | |
| (i) អត្ថប្រយោជន៍លើផលវិបាកក្នុងកំឡុងពេលមានផ្ទៃពោះ | រហូតដល់ US$2,000 | រហូតដល់ US$5,000 | បង់ជូនពេញថ្លៃ | បង់ជូនពេញថ្លៃ | បង់ជូនពេញថ្លៃ |
| (ii) អត្ថប្រយោជន៍លើការសម្រាលកូន និងការថែទាំទារកទើបនឹងកើត | មិនធានា | មិនធានា | រហូតដល់ US$1,500 | រហូតដល់ US$3,000 | រហូតដល់ US$8,000 |
| **(F) អត្ថប្រយោជន៍លើការព្យាបាលបង្កឡើងពី ឬដោយពាក់ព័ន្ធនឹង វីរុសហ៊ីវ (HIV) ឬជំងឺអេដស៍ (AIDS)** | **មិនធានា** | **មិនធានា** | **មិនធានា** | **មិនធានា** | **បង់ជូនពេញថ្លៃ** |
| **(G) អត្ថប្រយោជន៍លើកទឹកចិត្តសម្រាប់ការមិនទាមទារសំណង** | **មិនធានា** | **US$50** | **US$150** | **US$200** | **US$300** |
| (i) អត្ថប្រយោជន៍លើការថែទាំដើម្បីបង្ការជំងឺផ្សេងៗ<br>• អត្ថប្រយោជន៍លើការពិនិត្យសុខភាពជាប្រចាំ<br>• អត្ថប្រយោជន៍លើការត្រួតពិនិត្យរកជំងឺផ្សេងៗ<br>• អត្ថប្រយោជន៍លើការចាក់ថ្នាំបង្ការ | មិនធានា | រហូតដល់ US$50 | រហូតដល់ US$150 | រហូតដល់ US$200 | រហូតដល់ US$300 |
| (ii) អត្ថប្រយោជន៍លើការថែទាំសុខភាពមាត់ធ្មេញ<br>• អត្ថប្រយោជន៍លើការថែទាំ និងពិនិត្យសុខភាពមាត់ធ្មេញជាប្រចាំ | | | | | |

# ការទទួលយកសំណើជានារ៉ាប់រង

086 999 242
kh.care@aia.com
aia.com.kh
AIA Cambodia Telegram Channel

# ករណីមិនធានា

## ករណីមិនធានាសម្រាប់អត្ថប្រយោជន៍លើមរណភាព

ក្រុមហ៊ុននឹងមិនធានាលើ មរណភាព ដែលកើតឡើងដោយផ្ទាល់ ឬដោយប្រយោល ពីករណីណាមួយខាងក្រោមនេះ៖

1. ការធ្វើអត្តឃាត ការធ្វើឱ្យរបួសខ្លួនឯង ទោះបីស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតី កំឡុងពេល 2 (ពីរ) ឆ្នាំចាប់ពីកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទដែលចូលជាធរមានដោយយកកាលបរិច្ឆេទចុងក្រោយគេ ឬ
2. ការប្រព្រឹត្ត ឬការប៉ុនប៉ងប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ ដោយម្ចាស់បណ្ណសន្យារ៉ាប់រង ឬដោយអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល ឬ
3. វីរុសហ៊ីវ និង/ឬជំងឺណាមួយដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ រួមទាំងជំងឺអេដស៍ និង/ឬការផ្លាស់ប្តូរ ការវិវឌ្ឍន៍ ឬការប្រែប្រួលនៃមេរោគអេដស៍ និង/ឬជំងឺដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ រួមទាំងជំងឺអេដស៍ ឬ
4. ការប្រើប្រាស់គ្រឿងញៀន ឬថ្នាំសប្បាយ ការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ដូចមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមានដូចជាច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ល។

## ករណីមិនធានាសម្រាប់អត្ថប្រយោជន៍លើពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍

ក្រុមហ៊ុននឹងមិនធានាលើពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ដែលកើតឡើងដោយផ្ទាល់ ឬដោយប្រយោល ទាំងស្រុង ឬដោយផ្នែកណាមួយ ពីករណីណាមួយខាងក្រោមនេះ៖

1. ការប្រឈមនឹងគ្រោះថ្នាក់ដោយចេតនា ឬប៉ុនប៉ងធ្វើបាបខ្លួនឯងដោយចេតនា ឬធ្វើឱ្យរបួសខ្លួនឯងទោះស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ ឬ
2. ការចូលបម្រើក្នុងជួរកងទ័ព ក្នុងកំឡុងពេលមានប្រកាស ឬគ្មានប្រកាសសង្គ្រាមក្តី ឬក្រោមបញ្ជាប្រតិបត្តិការសង្គ្រាម ឬការស្តារសណ្តាប់ធ្នាប់សាធារណៈ ឬ
3. ការចូលរួមក្នុងការធ្វើដំណើរតាមផ្លូវអាកាស លើកលែងតែអ្នកត្រូវបានធានារ៉ាប់រងជាអ្នកដំណើរធម្មតាក្នុងយន្តហោះពាណិជ្ជកម្មដែលបានចុះបញ្ជីត្រឹមត្រូវ ឬ
4. ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ដែលបណ្តាលមកពីបញ្ហាផ្លូវកាយ ឬផ្លូវចិត្ត ដែលកើតមានមុនកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទដែលចូលជាធរមានដោយយកកាលបរិច្ឆេទចុងក្រោយគេ ហើយដែលមិនបានបង្ហាញក្នុងពាក្យស្នើសុំ ឬរបាយការណ៍សុខភាព ឬ
5. ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ប្រព្រឹត្ត ឬប៉ុនប៉ងនឹងប្រព្រឹត្ត ដោយម្ចាស់បណ្ណសន្យារ៉ាប់រង ឬដោយអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល ឬ
6. ការប្រើប្រាស់គ្រឿងញៀន ឬថ្នាំសប្បាយ ការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ដូចមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមានដូចជា ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ល។

## ករណីមិនធានាពាក់ព័ន្ធនឹងទណ្ឌកម្មអន្តរជាតិ

1. ក្រុមហ៊ុនអាចលុបចោលបណ្ណសន្យារ៉ាប់រងនេះនៅពេលណាមួយក៏បាន (ដោយការលុបចោលនេះមានសុពលភាពគិតចាប់ពីកាលបរិច្ឆេទចេញបណ្ណសន្យារ៉ាប់រង ឬផ្សេងពីនេះ) តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់បណ្ណសន្យារ៉ាប់រង ក្នុងករណីដែលម្ចាស់បណ្ណសន្យារ៉ាប់រង ឬបុគ្គល ឬអង្គភាពណាមួយដែលពាក់ព័ន្ធនៅក្នុងបណ្ណសន្យារ៉ាប់រងនេះ តាមការយល់ឃើញរបស់ក្រុមហ៊ុន ត្រូវបានរកឃើញថាបានបង្ក ឬអាចនឹងបង្កហានិភ័យផ្នែកទណ្ឌកម្ម ការហាមប្រាម ឬការរឹតបន្តឹងមកដល់ក្រុមហ៊ុនតាមរយៈសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ឬការដាក់ទណ្ឌកម្មផ្នែកសេដ្ឋកិច្ច/ពាណិជ្ជកម្ម លិខិតបទដ្ឋានគតិយុត្តិរបស់សហភាពអឺរ៉ុប ចក្រភពអង់គ្លេស ឬសហរដ្ឋអាមេរិក ឬតាមការអនុវត្តច្បាប់ ឬបទបញ្ញត្តិផ្សេងៗស្តីពីការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ឬពាណិជ្ជកម្ម។ ក្រុមហ៊ុន នឹងមិនធ្វើប្រតិបត្តិការអាជីវកម្មជាមួយម្ចាស់បណ្ណសន្យារ៉ាប់រង ដែលពាក់ព័ន្ធនឹងបណ្ណសន្យារ៉ាប់រងនេះនោះទេ ដោយរួមបញ្ចូល ប៉ុន្តែមិនកម្រិតត្រឹមការផ្តល់ ឬទទួលទូទាត់ទឹកប្រាក់ក្រោមបណ្ណសន្យារ៉ាប់រងនេះ។
2. ដោយមិនមានការប៉ះពាល់ដល់សុពលភាពកថាខណ្ឌ (1) ខាងលើនៃប្រការនេះទេ បណ្ណសន្យារ៉ាប់រងនេះនឹងត្រូវចាត់ទុកថា មិនត្រូវផ្តល់ការធានាណាមួយឡើយ ហើយក្រុមហ៊ុនក៏មិនទទួលខុសត្រូវក្នុងការទូទាត់សំណង ឬផ្តល់អត្ថប្រយោជន៍ផ្សេងៗ ក្នុងទំហំដែលការផ្តល់ការការពារ ការទូទាត់សំណង ឬការផ្តល់ជូននូវអត្ថប្រយោជន៍ផ្សេងៗទាំងនោះ អាចនាំឱ្យក្រុមហ៊ុនប្រឈមមុខនឹងហានិភ័យនានាពាក់ព័ន្ធនឹងការដាក់ទណ្ឌកម្ម ការហាមប្រាម ឬការរឹតបន្តឹងក្រោមសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ឬការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ឬពាណិជ្ជកម្ម លិខិតបទដ្ឋានគតិយុត្តិរបស់សហភាពអឺរ៉ុប ឬចក្រភពអង់គ្លេស ឬសហរដ្ឋអាមេរិក ឬការអនុវត្តច្បាប់ ឬបទបញ្ញត្តិផ្សេងៗស្តីពីការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ឬពាណិជ្ជកម្ម។
3. ជាកាតព្វកិច្ចដែលត្រូវអនុវត្តបន្តជាប្រចាំ ម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវជូនដំណឹងជាបន្ទាន់ទៅកាន់ក្រុមហ៊ុន ប្រសិនបើមានករណីផ្លាស់ប្តូរអត្តសញ្ញាណ ស្ថានភាព (មុខដំណែង) លក្ខន្តិកៈ (ក្នុងករណីជាក្រុមហ៊ុន) ក្រុមហ៊ុនពាក់ព័ន្ធនឹងម្ចាស់បណ្ណសន្យារ៉ាប់រងក្រោមខ្លឹមសារនៃបណ្ណសន្យារ៉ាប់រងនេះ ព័ត៌មានលម្អិត និងឯកសារអត្តសញ្ញាណកម្មរបស់ម្ចាស់បណ្ណសន្យារ៉ាប់រង ឬបុគ្គល ឬអង្គភាពនានាដែលពាក់ព័ន្ធនឹងបណ្ណសន្យារ៉ាប់រងនេះ។

## ករណីមិនធានាសម្រាប់ផលិតផលធានារ៉ាប់រងបន្ថែមផ្នែកវិជ្ជាសាស្ត្រ

### ផលិតផលធានារ៉ាប់រងបន្ថែមនេះ មិនធានាលើចំណាយដែលកើតឡើង ដោយផ្ទាល់ ឬដោយប្រយោលពី៖

1. ស្ថានភាពមុនពេលធានារ៉ាប់រងណាមួយ ដែលបានកើតឡើងមុនកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទដែលចូលជាធរមាននៃផលិតផលធានារ៉ាប់រងបន្ថែមនេះ ដោយយកកាលបរិច្ឆេទណាមួយចុងក្រោយគេ ឬ
2. ការវះកាត់ និងការព្យាបាលកែសម្ផស្ស ឬការព្យាបាលដើម្បីកែលម្អរូបរាង ការព្យាបាលដើម្បីជម្រុះរោម ឬសក់ ឬបណ្តុះសក់ ការផ្លាស់ប្តូរពណ៌ស្បែក ឬពណ៌ភ្នែក លើកលែងការវះកាត់កែសម្រួលមុខងារប្រើប្រាស់បន្ទាប់ពីទទួលរងគ្រោះថ្នាក់ចៃដន្យ ឬការព្យាបាលដែលមានលក្ខខណ្ឌគ្រប់គ្រាន់ ឬ
3. ការព្យាបាលដែលចាំបាច់ដែលបណ្តាលមកពីផលប៉ះពាល់នៃផ្នែកវិទ្យុសកម្ម ជីវសាស្ត្រ ឬសារធាតុគីមី ដែលអ្នកត្រូវបានធានារ៉ាប់រង អាចចូលរួមក្នុងទំនាស់ សង្គ្រាម សកម្មភាពរបស់សត្រូវបរទេស ការឈ្លានពាន សង្គ្រាមស៊ីវិល បាតុកម្ម ការបះបោរ កុបកម្ម បដិវត្តន៍ ការផ្តួលរលំរដ្ឋាភិបាលស្របច្បាប់ ការផ្ទុះអាវុធនៃសង្គ្រាម ឬព្រឹត្តិការណ៍ណាមួយដែលប្រហាក់ប្រហែលនឹងព្រឹត្តិការណ៍ដែលបានរៀបរាប់នេះ។ទាំងនេះរាប់បញ្ចូលទាំងការព្យាបាលទាំងឡាយដែលបណ្តាលមកពីការប្រឈមខ្លួនទៅនឹងហានិភ័យរបស់អ្នកត្រូវបានធានារ៉ាប់រង ដូចជា ការទៅកាន់កន្លែងដែលមានចលាចលសង្គម មិនថាក្នុងនាមជាអ្នកឃ្លាំមើល ឬអ្នកទស្សនាក៏ដោយ។ សូមបញ្ជាក់ផងដែរថា ការធានានឹង ផ្តល់ជូនសម្រាប់ការព្យាបាលចាំបាច់ដែលបណ្តាលមកពីសកម្មភាពភេរវកម្ម ក្នុងករណីដែលសកម្មភាពនេះ មិនបានបណ្តាលមកពីផលប៉ះពាល់ផ្នែកវិទ្យុសកម្ម ជីវសាស្ត្រ ឬសារធាតុគីមី ឬ
4. ការព្យាបាលដែលបណ្តាលមកពីការចូលរួមនៅក្នុងសកម្មភាពកងទ័ព ឬសកម្មភាពកីឡាជាអាជីព ឬ
5. ការប្រើប្រាស់ឱសថដែលមិនមានការទទួលស្គាល់ថាមានប្រសិទ្ធភាព ឬឱសថដែលស្ថិតនៅក្នុងកំឡុងពេលការធ្វើពិសោធន៍នៅឡើយ។ នេះមានន័យថា ឱសថទាំងនោះត្រូវទទួលបានអាជ្ញាប័ណ្ណដោយភ្នាក់ងារឱសថ អឺរ៉ុប (the European Medicines Agency) ប្រសិនបើ អ្នកត្រូវបានធានារ៉ាប់រងទទួលការព្យាបាល នៅក្នុងសហភាពអឺរ៉ុប ឬពីរដ្ឋបាលផ្នែកឱសថ និងចំណីអាហារនៃសហរដ្ឋអាមេរិក (the US Food and Drug Administration (FDA)) ប្រសិនបើ អ្នកត្រូវបានធានារ៉ាប់រងទទួលការព្យាបាលនៅកន្លែងផ្សេងទៀតនៅក្នុងសកលលោក ហើយឱសថនោះត្រូវបានប្រើប្រាស់ក្នុងលក្ខខណ្ឌនៃអាជ្ញាបណ្ណនោះតែប៉ុណ្ណោះ ឬ
6. ការព្យាបាលដែលមិនមានការទទួលស្គាល់ថាមានប្រសិទ្ធភាពឬការព្យាបាលដែលស្ថិតនៅក្នុងកំឡុងពេលការធ្វើពិសោធន៍នៅឡើយ។សម្រាប់ការព្យាបាលដែលមានការទទួលស្គាល់នេះ មានន័យថា ជាវិធីសាស្ត្រ និងការអនុវត្តនានា ដែលបានឆ្លងកាត់ការសាកល្បង និងការវាយតម្លៃផ្នែកវេជ្ជសាស្ត្រយ៉ាងត្រឹមត្រូវ និងត្រូវបានផ្តល់ភស្តុតាងយ៉ាងគ្រប់គ្រាន់នៅក្នុងសៀវភៅវេជ្ជសាស្ត្រ ដែលបានបោះផ្សាយ សម្រាប់គោលដៅជាក់លាក់មួយ ដើម្បីចាត់ទុកថាជាការបង្ហាញពីការព្យាបាលយ៉ាងមានសុវត្ថិភាព និងប្រសិទ្ធភាព ឬ
7. ការព្យាបាលឱ្យមានកូន ការពន្យារកំណើត ឬការបង្អាក់កំណើត ឬគ្រៀវ ឬការព្យាបាលក្នុងការពន្យារកំណើត ការកែភេទ អសមត្ថភាពផ្លូវភេទ ការវះកាត់ព្យាបាលគភ៌ ឬទារកនៅក្នុងផ្ទៃ ឬ
8. រាល់ការចំណាយដែលបង្កឡើងពី ឬពាក់ព័ន្ធនឹងការធ្វើចត្តាឡីស័ក (quaratine) ឬ
9. ការព្យាបាលដោយបុគ្គលដែលមិនមែនជាគ្រូពេទ្យ ឬគ្រូពេទ្យដែលមិនមានអាជ្ញាបណ្ណវិជ្ជាជីវៈត្រឹមត្រូវ ឬ
10. ចំណាយដែលមិនមែនសម្រាប់ការព្យាបាលជំងឺ ដូចជា ថ្លៃសេវាទូរស័ព្ទ ការជួលទូរទស្សន៍ សារព័ត៌មាន ផលិតផលផ្តល់សំណើមស្បែក គ្រីម គ្រឿងប្រដាប់សម្រាប់ងូតទឹក អាហារបំប៉ន និងវីតាមីន ថ្នាំដុសធ្មេញ ឬសាប៊ូ ឬ
11. ចំណាយដែលមិនប្រក្រតី មិនសមហេតុផល មិនមានភាពចាំបាច់ក្នុងការព្យាបាល ក្នុងតំបន់ដែលទទួលការព្យាបាល ឬ
12. ការព្យាបាលប្រឆាំងនឹងភាពធាត់ រួមមានដោយមិនកំណត់ត្រឹម ការចង ឬការវះកាត់ទាក់ទងនឹងក្រពះ ការយកចេញនូវកោសិកា និងខ្លាញ់ដែលលើស ឬ
13. ការព្យាបាលដែលជាធម្មតាមិនសម្រាកនៅក្នុងមន្ទីរពេទ្យ ដោយរួមបញ្ចូលទាំងឱសថ និងការរុំរបួស ការប្រឹក្សាយោបល់ និងការពិនិត្យតាមដានជំងឺ បូករួមទាំងការពិនិត្យកំឡុងពេលនិងក្រោយពេលមានផ្ទៃពោះ ការព្យាបាលជំងឺផ្លូវចិត្ត ឬ
14. ការពិនិត្យសុខភាពដើម្បីបង្ការជំងឺផ្សេងៗ ការពិនិត្យសុខភាព ការចាក់ថ្នាំបង្ការ ការធ្វើរោគវិនិច្ឆ័យ និងការពិនិត្យតាមដានជំងឺក្នុងដំណាក់កាលដំបូងនៃជំងឺដែលគ្មានរោគសញ្ញា លុះត្រាតែមានបង្ហាញនៅលើតារាងអត្ថប្រយោជន៍ ឬ
15. ការថែរក្សាសុខភាពមាត់ធ្មេញ និងអញ្ចាញធ្មេញ (ឬប្រហាក់ប្រហែល) លុះត្រាតែមានបង្ហាញនៅលើតារាងអត្ថប្រយោជន៍ ឬ
16. ការព្យាបាលភ្នែក ឬចក្ខុវិញ្ញាណ ឬ
17. ចំណាយសេវាវេជ្ជសាស្ត្រដែលកើតឡើងក្នុងរយៈពេលនៃការរង់ចាំ លើកលែងតែចំណាយសេវាវេជ្ជសាស្ត្រដែលបង្កឡើងពីគ្រោះថ្នាក់ចៃដន្យ ដែលកើតឡើងក្នុងរយៈពេលនៃការរង់ចាំដោយអនុលោមទៅតាមករណីមិនធានាដទៃទៀត ឬ
18. ការជំនួសសរីរាង្គខាងក្រៅ(ឧបករណ៍សិប្បនិម្មិត)និងឧបករណ៍ប្រើប្រាស់សម្រាប់ព្យាបាលជំងឺនិងឧបករណ៍ពាក់ព័ន្ធនានាក្រៅពីឧបករណ៍ទាំងឡាយណាដែលជាផ្នែកនៃការវះកាត់ ឬរួមបញ្ចូលក្នុងការព្យាបាល ឬ
19. ចំណាយលើការទទួលសរីរាង្គ ឬជាលិកាពីការបរិច្ចាគ ឬចំណាយរដ្ឋបាលដែលពាក់ព័ន្ធណាមួយ (រួមមាន តែមិនកំណត់ត្រឹមការចំណាយលើការស្វែងរកការបរិច្ចាគ) ឬ
20. ចំណាយបន្ថែមសម្រាប់ការទទួលបានរបាយការណ៍ពេទ្យ ឬការដាក់ពាក្យស្នើសុំទាមទារសំណង ឬចំណាយរដ្ឋបាលផ្សេងៗ ទៀត ឬ
21. ការព្យាបាលការញៀន (ដូចជា ការញៀនគ្រឿងស្រវឹង សារធាតុ ឬថ្នាំញៀន) ឬការប្រើប្រាស់សារធាតុញៀននានាលើសចំណុះ (ដូចជា ការប្រើប្រាស់គ្រឿងស្រវឹងលើសចំណុះ ឬការប្រើប្រាស់សារធាតុ ឬថ្នាំញៀនលើសចំណុះ) ឬតម្រូវការព្យាបាលព្យាបាលជំងឺ ឬរបួសនានា ដែលបង្កឡើងពីការការប្រើប្រាស់គ្រឿងស្រវឹងលើសចំណុះ ឬការញៀន មិនថាដោយផ្ទាល់ ឬដោយប្រយោលឡើយ ឬ
22. ចំណាយសេវាវេជ្ជសាស្ត្រដែលបង្កឡើងពី ឬដោយពាក់ព័ន្ធនឹងវីរុសហ៊ីវ (HIV) និង/ឬ ជំងឺដែលពាក់ព័ន្ធនឹងវីរុសហ៊ីវ (HIV) ដោយរាប់បញ្ចូលទាំងជំងឺអេដស៍ ឬរោគសញ្ញារបស់ជំងឺអេដស៍ និង/ឬ រោគសញ្ញានានាដែលបំប្លែងពីរោគសញ្ញានៃជំងឺអេដស៍នេះ លុះត្រាតែមានបង្ហាញនៅលើតារាងអត្ថប្រយោជន៍ ឬ
23. ការចាក់ថ្នាំបង្ការក្រៅពីការចាក់ថ្នាំបង្ការលើកដំបូងសម្រាប់ទារកទើបនឹងកើតដែលបានធានាក្រោមអត្ថប្រយោជន៍លើការសម្រាលកូននិងការថែទាំទារកទើបនឹងកើតដូចមានបង្ហាញនៅលើតារាងអត្ថប្រយោជន៍ ឬ
24. ការសម្រាលកូន និងការថែទាំទារកទើបនឹងកើត លុះត្រាតែមានបង្ហាញនៅលើតារាងអត្ថប្រយោជន៍ ឬ
25. គ្រែបន្ថែមសម្រាប់អាណាព្យាបាល ឬអ្នកកំដរ ខណៈពេលដែលអ្នកត្រូវបានធានារ៉ាប់រងចូលសម្រាកក្នុងមន្ទីរពេទ្យលុះត្រាតែមានបង្ហាញនៅលើតារាងអត្ថប្រយោជន៍ ឬ
26. ការថែទាំរបស់គិលានុបដ្ឋាកតាមផ្ទះ លុះត្រាតែមានបង្ហាញនៅលើតារាងអត្ថប្រយោជន៍ ឬ
27. ការថែទាំជំងឺផ្លូវចិត្ត លុះត្រាតែមានបង្ហាញនៅលើតារាងអត្ថប្រយោជន៍ ឬ
28. សេវាកម្មថែទាំអ្នកជំងឺដំណាក់កាលចុងក្រោយ លុះត្រាតែមានបង្ហាញនៅលើតារាងអត្ថប្រយោជន៍ ឬ
29. ចំណាយណាមួយដែលកើតឡើងខណៈពេលអ្នកត្រូវបានធានារ៉ាប់រងស្ថិតនៅក្រៅព្រះរាជាណាចក្រកម្ពុជារយៈពេល 90 (កៅសិប) ថ្ងៃជាប់គ្នា ឬច្រើនជាងនេះ ក្នុងកំឡុងពេល 1 ឆ្នាំនៃបណ្ណសន្យារ៉ាប់រង។

## ការិយាល័យកណ្ដាល

អគារ ជីអាយអេ ថៅអឺរ ជាន់ទី31 ផ្លូវសុភមង្គល ភូមិ14 សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

## សាខាសៀមរាប

អគារលេខ 29 និង 30
ផ្លូវហ្សាលដីហ្គោល សាលាកន្សែង សង្កាត់ស្វាយដង្គំ ទីរួមខេត្តសៀមរាប

## សាខាបាត់ដំបង

ផ្ទះលេខ 2-6ផ្លូវលេខ 3 ភូមិកម្មករ សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង

## សាខាកំពង់ចាម

ភូមិ 15 សង្កាត់កំពង់ចាម ខណ្ឌកំពង់ចាម ខេត្តកំពង់ចាម

## សាខាកំពត

ផ្លូវលេខ 700 ភូមិ 1ឧសភា សង្កាត់កំពង់កណ្ដាល ក្រុងកំពត ខេត្តកំពត